**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ចាម**

លេខ០៧៣/១៧ សសរ

កំពង់ចាម ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

**ស្តីពី**

**បង្កើតអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិដើម្បីរៀបចំបញ្ជីឈ្មោះអ្នកទទួលការសម្រាប់ឆ្នាំ២០១៨**

**អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥០៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម។
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០០៨ស្តីពី ការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហៅកាត់ថា គ.ជ.អ.ប ។
- បានឃើញសេចក្តីជូនដំណឹង លេខ ៥៩៧សជណ/គ.ជ.អ.ប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៨ របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

**សម្រេច**

<u>**ប្រការ១:**</u> បង្កើតអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិអ្នកទទួលការឆ្នាំ ២០១៨ ខេត្តកំពង់ចាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.លោក **យន ប្រុស** | នាយករដ្ឋបាល សាលាខេត្ត | ជាប្រធាន |
| ២.លោក **ប្រាក់ ទិត្យ** | នាយកទីចាត់ការផែនការ និងវិនិយោគ | ជាអនុប្រធាន |
| ៣.លោក **អ៊ុំ ប៊ុណ្ណាកា** | នាយករងទីចាត់ការផែនការ និងវិនិយោគ | ជាសមាជិក |
| ៤.លោក **ពោយ សុខជា** | នាយករងទីចាត់ការផែនការ និងវិនិយោគ | ជាសមាជិក |
| ៥.លោក **ផ្លោក សុវណ្ណ** | ចៅសង្កាត់កំពង់ចាម ក្រុងកំពង់ចាម | ជាសមាជិក |
| ៦.លោក **សន សុខ** | មេឃុំកោះសំរោង ស្រុកកំពង់សៀម | ជាសមាជិក |
| ៧.លោក **ចេង សំណាង** | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិប្រចាំខេត្ត | ជាសមាជិក |
| ៨.លោក **សូ សារ៉ន** | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ខេត្ត | ជាសមាជិក |
| ៩.លោក **គុល កណាល់** | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន | ជាលេខាធិការ |

**ប្រការ២:** អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិវាយតម្លៃអ្នកទទួលការ ឆ្នាំ២០១៨ មានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- រៀបចំប្រកាសជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៨ ជាសាធារណៈ និងមានតម្លាភាព ប្រកាសផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈក្តារព័ត៌មានសាលាខេត្ត ខាងមុខទីចាត់ការផែនការ និងវិនិយោគខេត្ត សាលាក្រុងស្រុក វិទ្យុ ទូរទស្សន៍ក្នុងខេត្ត និងគេហទំព័រលេខាធិការដ្ឋាន គ.ជ.អ.ប ។
- រៀបចំប្រជុំផ្សព្វផ្សាយស្តីពីនីតិវិធី និងដំណើរការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០១៨។
- កំណត់កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំចុះឈ្មោះអ្នកទទួលការ ប្រកបដោយតម្លាភាព។
- ពិនិត្យសំណុំឯកសារដាក់ពាក្យអ្នកទទួលការ និងរៀបចំចាត់តាំងក្រុមការងារ ដើម្បីចុះវាយតម្លៃស្នាដៃ បទពិសោធន៍បុគ្គលិកបច្ចេកទេសសម្ភារៈ គ្រឿងចក្រអ្នកទទួលការដល់ទីកន្លែង។
- សហការជាមួយទីចាត់ការផែនការ និងវិនិយោគ ដើម្បីជួយជម្រុញឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើការវាយតម្លៃការងាររបស់អ្នកទទួលការឆ្នាំ២០១៦ និងឆ្នាំ២០១៧ ព្រមទាំងបូកសរុបរបាយការណ៍។
- រៀបចំរបាយការណ៍វាយតម្លៃរបស់អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ បញ្ជីឈ្មោះ អ្នកទទួលការដែលមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងរៀបចំកំណត់ហេតុ របាយការណ៍ ឯកសារពាក់ព័ន្ធនានាដើម្បីដាក់ជូន ឯកឧត្តមអភិបាលខេត្តពិនិត្យ និងសម្រេច។

**ប្រការ៣:** សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤:** នាយករដ្ឋបាលសាលាខេត្ត ទីចាត់ការទាំងប្រាំ និងអង្គភាពលទ្ធកម្មចំណុះសាលាខេត្ត អភិបាលក្រុង-ស្រុក មេឃុំ-ចៅសង្កាត់ទាំងអស់ក្នុងខេត្ត មន្ទីរ-អង្គភាពពាក់ព័ន្ធ និងអស់លោក លោកស្រី ដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តន៍តាមសេចក្តីសម្រេចនេះ ឲ្យទទួលបានលទ្ធផលល្អប្រសើរ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ៤/

**អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម**

គួច_ចំរើន

**កន្លែងទទួល**

-ក្រសួងមហាផ្ទៃ
-លេខាធិការដ្ឋាន គ.ជ.អ.ប
-ក្រុមប្រឹក្សាខេត្ត
(ដើម្បីជូនជ្រាប)
-ដូចប្រការ៤
-ឯកសារកាលប្បវត្តិ